Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយបន្ទាន់

# អាល្លឺម៉ង់សន្យាផ្ដល់ថវិកា ៤ លានអឺរ៉ូ ដើម្បីពង្រឹង កិច្ចសហប្រតិបត្តិការធនធានទឹកឆ្លងដែនក្នុងតំបន់ទន្លេមេគង្គ

**ទីក្រុងវៀងចន្ទ ថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១៨** – រដ្ឋាភិបាលអាល្លឺម៉ង់ បានសន្យាផ្ដល់ប្រាក់ចំនួន ៤ លានអឺរ៉ូ (ប្រមាណ ៤,៦ លានដុល្លារសហរដ្ឋអាមេរិក) ដល់គណៈកម្មការទន្លេមេគង្គ ដែលហៅកាត់ថា MRC ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការធនធានទឹកឆ្លងដែន ក្នុងតំបន់ទន្លេមេគង្គ។

ការគាំទ្ររបស់អាល្លឺម៉ង់នេះ មានគោលបំណងបង្កើនកិច្ចពិភាក្សា និង លើកកម្ពស់កិច្ចសហប្រតិបត្តិការ ជុំវិញការរៀបចំផែនការ និងការគ្រប់គ្រងធនធានទឹកឆ្លងដែន រវាងបណ្ដាប្រទេសតាមដងទន្លេមេគង្គក្រោម រួមមាន កម្ពុជា ឡាវ ថៃ និងវៀតណាម ដែលជាសមាជិករបស់ MRC។

ថវិកានេះ នឹងត្រូវប្រើប្រាស់សម្រាប់រយៈពេល ៣ឆ្នាំ គិតចាប់ពីខែមករា ឆ្នាំ២០១៩ រហូតដល់ ខែធ្នូ ឆ្នាំ២០២១។ ការអនុវត្តថវិកានេះ នឹងធ្វើឡើងតាមរយៈអង្គការអភិវឌ្ឍន៍បច្ចេកទេសអាល្លឺម៉ង់ ដែលហៅកាត់ថា GIZ នេះបើតាមលិខិតផ្លូវការដែលស្ថានទូតអាល្លឺម៉ង់ប្រចាំទីក្រុងវៀងចន្ទ ផ្ញើជូនលេខាធិការដ្ឋាន MRC កាលពីចុងសប្ដាហ៍មុននេះ។

លោក ផាំ ទាន់ផាន (Pham Tuan Phan) នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC មានប្រសាសន៍ថា "ការបន្តរួមចំណែកពីប្រទេសអាល្លឺម៉ង់នេះ នឹងជួយពង្រឹងដល់កិច្ចខិតខំប្រឹងប្រែងរបស់ MRC ក្នុងការធ្វើឱ្យកាន់តែប្រសើរឡើងនូវការរៀបចំផែនការ និងការគ្រប់គ្រងតំបន់អាងទន្លេរួមគ្នា ដែលមានលក្ខណៈចូលរួម និងសម្របសម្រួលជាងមុន ខណៈពេលដែលតំបន់អាងទន្លេមេគង្គកំពុងមានការអភិវឌ្ឍ និងការផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស"។

ថវិកាភាគច្រើន នឹងចំណាយសម្រាប់គាំទ្រដល់ការអនុវត្តគម្រោងរួមគ្នាចំនួនពីរ ដែលជាគម្រោងមានលក្ខណៈឆ្លងដែន រវាងកម្ពុជានិងឡាវ និង រវាងកម្ពុជានិងថៃ។ គម្រោងទាំងពីរនេះ មានគោលបំណងធ្វើការស្វែងយល់ពីធនធានក្នុងតំបន់អាងទន្លេ និងគ្រប់គ្រងធនធានទាំងនេះឱ្យបានកាន់តែល្អប្រសើរ ក៏ដូចជាឆ្លើយតបចំពោះបញ្ហាទឹកជំនន់ និងគ្រោះរាំងស្ងួត។ បច្ចុប្បន្ន គម្រោងទាំងនេះ កំពុងស្ថិតនៅក្នុងដំណាក់កាលសាកល្បង ដែលនឹងបញ្ចប់នៅឆ្នាំនេះ ហើយដែលបានទទួលការគាំទ្រពីអាល្លឺម៉ង់ តាមរយៈយន្តការផ្ដល់ថវិកាស្រដៀងគ្នានេះដែរ។

មួយចំណែកនៃថវិកានេះ ក៏នឹងផ្ដល់ដល់ប្រព័ន្ធហិរញ្ញវត្ថុថ្មីរបស់ MRC ដែលមានឈ្មោះថា "មូលនិធិរួម" ឬ basket fund ដើម្បីដំណើរការសកម្មភាពនានា ដែលត្រូវបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រ ២០១៦-២០២០។ ប្រព័ន្ធថវិកាថ្មីនេះ ផ្ដល់លទ្ធភាពឱ្យ MRC ប្រើប្រាស់មូលនិធិដែលមានស្រាប់ សម្រាប់សកម្មភាពជាអាទិភាពនានា ដែលនាំឱ្យមានការឆ្លើយតបចំពោះតម្រូវការថ្មីៗ ទាន់ពេលវេលា និងធ្វើឱ្យការ

អនុវត្តគម្រោងកាន់តែមានភាពល្អប្រសើរជាងមុន សំដៅផ្ដល់ប្រយោជន៍ដល់ប្រជាពលរដ្ឋជាង ៦៥ លាននាក់ ដែលកំពុងរស់នៅក្នុងអាងទន្លេមេគង្គក្រោម។

គេរំពឹងថា កិច្ចសហប្រតិបត្តិការរវាងអាល្លឺម៉ង់ និង MRC នឹងបង្ហាញឱ្យឃើញពីរបៀប ដែលរដ្ឋជាសមាជិករបស់ MRC អាចធ្វើការងាររួមគ្នានៅកម្រិតទ្វេភាគី ដើម្បីឆ្លើយតបចំពោះបញ្ហានានា ដែលកំពុងកើតមានជាក់ស្ដែង ក្នុងប្រទេសរបស់ពួកគេ ឱ្យកាន់តែមានប្រសិទ្ធភាពជាងមុនទៀត។

លោក Bertrand Meinier នាយកកម្មវិធីសហប្រតិបត្តិការ MRC – GIZ មានប្រសាសន៍ថា "ការផ្ដល់ធនធានហិរញ្ញវត្ថុរបស់យើងនៅថ្ងៃនេះ គឺជាការជួយគាំទ្របន្ថែមទៀត ដល់កិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងតំបន់ទន្លេមេគង្គ ដែលអនុវត្តដោយ MRC ដើម្បីធានាឱ្យមានការបន្តកិច្ចពិភាក្សា និងកិច្ចសហប្រតិបត្តិការឱ្យបានរឹងមាំ ក្នុងចំណោមប្រទេសមេគង្គ និងផ្ដល់នូវការការពារទាន់ពេលវេលា និងការគ្រប់គ្រងប្រកបដោយចីរភាព នូវធនធានទឹកក្នុងទន្លេមេគង្គ"។

ប្រទេសអាល្លឺម៉ង់បានផ្ដល់ថវិកាដល់ MRC ចាប់តាំងពីឆ្នាំ ២០០៣ មក ជាមួយនឹងទឹកប្រាក់ប្រមាណជា ៣១ លានអឺរ៉ូ ឬ ៣៦ លានដុល្លារសហរដ្ឋអាមេរិក។ ក្នុងរយៈពេល ១៥ ឆ្នាំ កន្លងមកនេះ ការគាំទ្ររបស់អាល្លឺម៉ង់ បានធ្វើឱ្យ MRC អាចមានលទ្ធភាពអភិវឌ្ឍសកម្មភាពយុទ្ធសាស្ត្រជាច្រើន ដូចជា កំណែទម្រង់ស្ថាប័ន ការអភិវឌ្ឍវារីអគ្គិសនីប្រកបដោយចីរភាព ការគ្រប់គ្រងធនធានទឹកចំរុះ ការកាត់បន្ថយគ្រោះទឹកជំនន់ និងការប្រែប្រួលអាកាសធាតុ។

កិច្ចព្រមព្រៀងហិរញ្ញវត្ថុ សម្រាប់មូលនិធិថ្មីនេះ នឹងត្រូវចុះហត្ថលេខារវាងអាល្លឺម៉ង់ និង MRC នាចុងឆ្នាំនេះ។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្ដុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក មាស សុភក្រ្ត

មន្ត្រីទំនាក់ទំនងជាមួយអ្នកសារព័ត៌មាន

ទូរសព្ទ៖ (៨៥៦)-២១-២៦៣២៦៣ ភ្ជាប់បន្ត ៤០៧០

ទូរសព្ទដៃ៖ (៨៥៦)-២០-៧៧៧៧៩១៦៨

###